## ១. ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឱ្យបាន សមស្របតាមតម្រូវការទាំងក្នុង និងក្រៅប្រទេស

យើងទទួលស្គាល់ថាដៃគូក្នុងផ្នែកសេដ្ឋកិច្ច និងទីផ្សារការងារជាតួអង្គសំខាន់ក្នុងបរិធាននៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីធានាដល់សិស្ស និស្សិតដែលបានបញ្ចប់ការសិក្សាក្នុងផ្នែកនេះទទួលបានការងារធ្វើ ។ ដូចនេះត្រូវធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងរវាងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងទីផ្សារការងារ ដោយកសាងឡើងនូវខឿនអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មួយឆ្លើយតបទៅនឹងសំណូមពរអភិវឌ្ឍសេដ្ឋកិច្ច ទាំងផ្នែកសេដ្ឋកិច្ចរៀបរយ និងមិនរៀបរយ ។ អាស្រ័យហេតុនេះ យុទ្ធសាស្ត្រដើម្បីសម្រេចគោលដៅនេះរួមមាន :

### ១.១. បញ្ចូលតួអង្គពាក់ព័ន្ធទាំងឡាយក្នុងបុព្វហេតុនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

- តាមរយៈគណៈកម្មាធិការជាតិបណ្តុះបណ្តាល ត្រូវបង្កើតយន្តការមួយទទួលបន្ទុកខាងព័ត៌មានទីផ្សារការងារ ។ យន្តការនេះមានសមាសភាពចំរុះតំណាងគ្រប់ស្ថាប័ន និង អង្គភាពពាក់ព័ន្ធដើម្បី ពិភាក្សាផ្តល់យោបល់ និងឆ្លុះ បញ្ចាំងពីតម្រូវការកំលាំងពលកម្ម និងផែនការថ្នាក់ជាតិ សម្រាប់អភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ

- គ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវបង្កើតការិយាល័យ ឬក្រុមការងារមួយទទួលបន្ទុក ធ្វើការទំនាក់ទំនងជាមួយរោងចក្រសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនឯកជននានា ដើម្បីធ្វើការផ្លាស់ប្តូរយោបល់គ្នា នូវអ្វីជាតម្រូវការអ្នកប្រើប្រាស់កំលាំងពលកម្មដោយ ធានាឱ្យបានការបណ្តុះបណ្តាលជំនាញប្រកបដោយគុណភាព និងមានប្រសិទ្ធភាព
- គ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយដែលមានសមាស ភាពតំណាងពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីធ្វើការតម្រង់ទិស ការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។

## ១.២. ការជ្រើសរើសមុខជំនាញ និងរូបភាពបណ្តុះ-បណ្តាល ឱ្យបានសមស្រប

ការជ្រើសរើសមុខជំនាញ និងរូបភាពបណ្តុះបណ្តាលជាកត្តាមួយយ៉ាងសំខាន់បានជះឥទ្ធិពលដល់លទ្ធផលនៃការអប់រំ បណ្តុះបណ្តាល

បច្ចេកទេស និងវិជ្ជាជីវៈ ។ ដូចនេះត្រូវយកចិត្តទុកដាក់ផ្តល់មុខជំនាញបំរើឱ្យទាំងផ្នែកសេដ្ឋកិច្ចរៀបរយ និងមិនរៀបរយ ។ យុទ្ធសាស្ត្រនេះសំដៅគាំទ្រសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងតំបន់ និងជនបទដែលមានផ្នែកសំខាន់ៗដូចជា ដាំដុះថែទាំដំណាំ ចិញ្ចឹមសត្វ ឧស្សាហកម្មធុនតូចមធ្យម ជំនួញ សិប្បកម្ម ដឹកជញ្ជូន ទេសចរណ៍ ។ល។ ចំពោះរូបភាពបណ្តុះបណ្តាលត្រូវអនុវត្តន៍តាមបែបពហុសណ្ឋាន មានតាមរបៀបក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ជាពិសេសបណ្តុះបណ្តាល នៅតាមកន្លែងធ្វើការតាមរោងជាង រោងចក្រ សហគ្រាស កសិដ្ឋាន ។ល។

## ១.៣. ការលើកកំពស់ស្មារតីសហគ្រិនក្នុងការបណ្តុះ-បណ្តាល

- អភិវឌ្ឍស្មារតីសហគ្រិន ដើម្បីផ្តល់សមត្ថភាពចាំបាច់ក្នុងការគ្រប់គ្រងសហគ្រាសឱ្យបានល្អ ឬ ការបង្កើតមុខរបរដោយខ្លួនឯង
- ធ្វើអត្តសញ្ញាណកម្មផ្នែកសេដ្ឋកិច្ចសមស្រប ដើម្បីបង្កើតសហគ្រិនទៅតាមតម្រូវការសេដ្ឋកិច្ចសង្គម
- ផ្តល់ឥណទានខ្នាតតូចដល់ក្រុមសិក្ខាកាម សិស្ស និស្សិត ដែលបានបញ្ចប់ការសិក្សាផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មានលទ្ធភាពបង្កើតមុខរបរដោយខ្លួនឯង ។

### 1.1- ***ការលើកកំពស់គុណភាព និងប្រសិទ្ធភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ***

បញ្ហាគុណភាព ជាកត្តាចំបងមួយក្នុងបញ្ហាផ្សេងៗឯទៀត ដែលធ្វើឱ្យសិក្ខាកាម សិស្ស និងនិស្សិត ពេលរៀនចប់មានការលំបាក ស្វែង រកការងារធ្វើ និងប្រកបមុខរបរដោយខ្លួនឯង ។ ពាក់ព័ន្ធបញ្ហានេះ យើងត្រូវមានយុទ្ធសាស្ត្រ បង្កើននូវគុណភាពបណ្តុះបណ្តាលមួយសមស្រប តាមស្តង់ដាតម្រូវការទីផ្សារទាំងក្នុងប្រទេស និងក្រៅប្រទេស ។ ហេតុនេះទាមទារឱ្យក្រសួងរៀបចំនូវសកម្មភាពការងារមួយចំនួន ដែលត្រូវបំពេញ ដូចខាងក្រោម :

## ក. ការអភិវឌ្ឍធនធានមនុស្ស

- បណ្តុះបណ្តាលមន្ត្រីបច្ចេកទេសតាមផ្នែក និងគ្រូតាមជំនាញ នីមួយៗ តាមរយៈការប្រជុំសិក្ខាសាលា ទស្សនកិច្ចសិក្សា បើកវគ្គបណ្តុះបណ្តាលក្នុងស្រុកឬបញ្ជូនទៅធ្វើកម្មសិក្សា នានានៅក្រៅប្រទេស ។ល។
- បង្កើតក្រុមការងារតាមជំនាញនីមួយៗ ដើម្បីផ្ទេរចំណេះដឹង និងផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមក តាមរយៈ ការប្រជុំប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ
- រៀបចំឱ្យមានបណ្ណាល័យសិក្សាស្រាវជ្រាវ សម្រាប់បង្កើន

សមត្ថភាពជូនដល់មន្ត្រីរាជការគ្រូបច្ចេកទេស/ឯកទេស ។

- រៀបចំ និងជួយសម្រួលដល់មន្ត្រីរាជការគ្រូបច្ចេកទេស/ ឯកទេស ឱ្យមានលទ្ធភាពសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក
- ជម្រុញឱ្យអង្គភាពនីមួយៗភ្ជាប់បណ្ដាញ និងប្រើប្រាស់ ប្រព័ន្ធអេឡិចត្រូនិក ។

## ៦. ការអភិវឌ្ឍកម្មវិធីសិក្សា

- យកវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស (National Tech- nical Training Institute – NTTI ) ជា មជ្ឈមណ្ឌលជាតិសម្រាប់អភិវឌ្ឍកម្មវិធីសិក្សាផ្នែកអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងជាទីកន្លែង បណ្ដុះបណ្ដាល និងបំប៉នសមត្ថភាពគ្រូបច្ចេកទេស/ ឯកទេស
- បង្កើតឱ្យមានគណៈកម្មការបច្ចេកទេសថ្នាក់ជាតិតាម ជំនាញនីមួយៗ ដោយមានការចូលរួមពីជំនាញការតាម សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុននានា តំណាងកម្មករ ជំនាញ និងគ្រូបច្ចេកទេស/ ឯកទេស ដើម្បីអភិវឌ្ឍកម្មវិធីសិក្សាដែលមានទីតាំងអចិន្ត្រៃយ៍នៅ NTTI ហើយ គណៈកម្មការត្រូវប្រជុំរៀងរាល់ឆ្នាំ

- បង្កើតឱ្យមាន គណៈកម្មការ/ក្រុមការងារអភិវឌ្ឍន៍កម្ម វិធីសិក្សាតាមជំនាញនីមួយៗនៅគ្រប់គ្រឹះស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- អភិវឌ្ឍកម្មវិធីសិក្សាផ្អែកលើ ស្តង់ដាជាតិសមត្ថភាព

(National Competency standards) ដែលអាចធានាបានថានឹងផ្តល់នូវ សមត្ថភាពគ្រប់គ្រាន់ដែលទីផ្សារការងារចង់បាន

- អភិវឌ្ឍកម្មវិធីសិក្សាផ្អែកលើសមត្ថភាពដោយអនុវត្តតាម ប្រពន្ធ័ម៉ូឌុល (Modular system) ដែលនឹងសម្រួល ដល់ការចេញ និង ចូលរបស់សិក្ខាកាម សិស្ស និងនិស្សិត
- អភិវឌ្ឍកម្មវិធីសិក្សាបណ្តុះបណ្តាលរយៈពេលខ្លីៗទៅតាម ម៉ូឌុល ដើម្បីជួយដល់កម្មករឱ្យមានអាជីពកាន់តែប្រសើរឡើងព្រមទាំងទទួលបានកម្រៃកាន់តែខ្ពស់ជាងមុន
- រៀបចំកម្មវិធីសិក្សាឱ្យមានវគ្គ ឬថ្នាក់ចម្លង ( Bridging courses ) ដែលជាឱកាសអនុញ្ញាតឱ្យសិក្ខាកាម សិស្ស និងនិស្សិតមានលទ្ធភាពអាចឆ្លងទៅវិញទៅមករវាងផ្នែកចំណេះទូទៅ

និងផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។

## គ. ការអភិវឌ្ឍ និងបំពាក់មូលដ្ឋានសំភារៈ

- ធ្វើសនិទានកម្ម (Rationalization) លើមូលដ្ឋានសម្ភារៈ អគារសិក្សាដែលមានស្រាប់ ដើម្បីប្រើឱ្យអស់លទ្ធភាព
- បំពាក់ឧបករណ៍សម្ភារៈឧបទេសទំនើបបន្ថែមទៀតទៅលើគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលមានស្រាប់
- ជម្រុញឱ្យគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ នីមួយៗចេះច្នៃប្រឌិត និងបង្កើតសម្ភារៈឧបទេសបង្រៀនដោយខ្លួនឯង
- សង់មជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជា- ជីវៈបន្ថែមទៀត និងបំពាក់ឧបករណ៍សម្ភារៈឧបទេស ជាពិសេសចំពោះខេត្តដែលមិនទាន់មានមជ្ឈមណ្ឌលបណ្តុះ- បណ្តាលវិជ្ជាជីវៈខេត្ត
- បង្កើនគម្រោងថវិកាប្រចាំឆ្នាំនីមួយៗសម្រាប់ចំណាយលើមូលដ្ឋានសម្ភារៈបណ្តុះបណ្តាលឱ្យបាន គ្រប់គ្រាន់ទៅតាមសេចក្តីត្រូវការរបស់វគ្គបណ្តុះបណ្តាលនីមួយៗ ។

## ឃ. ការធ្វើវិមជ្ឈការកម្មវិធីបណ្តុះបណ្តាល

- អប់រំបណ្តុះបណ្តាលដល់ប្រជាពលរដ្ឋបានយល់ច្បាស់ពីសារ- សំខាន់នៃកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ

- ពង្រឹងការងារក្រុមប្រឹក្សា ឃុំ-សង្កាត់ និងគណៈកម្មា- ធិការខេត្ត-ក្រុង បណ្តុះបណ្តាលពាក់ព័ន្ធការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឱ្យកាន់តែប្រសើរឡើងពិសេសសិក្សាស្រាវជ្រាវរកជំនាញដែលជាតម្រូវការរបស់ខ្លួនដើម្បីធ្វើផែនការ និងកម្មវិធីសិក្សាសម្រាប់អប់រំបណ្តុះបណ្តាល

- ជម្រុញ និងលើកទឹកចិត្តដល់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង ឱ្យជួយសម្របសម្រួលជាមួយក្រុម ប្រឹក្សា ឃុំ-សង្កាត់និងប្រជាពលរដ្ឋក្នុងការរៀបចំផែនការ និងដំណើរការកម្មវិធីបណ្តុះបណ្តាល

- ជម្រុញឱ្យ ឃុំ-សង្កាត់ ស្រុក-ខណ្ឌ និងខេត្ត-ក្រុងនីមួយៗ

រៀបចំធ្វើផែនការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ដោយខ្លួនឯង

- ផ្តល់សិទ្ធិអំណាច ឱ្យទៅតាមឋានានុក្រមនៅតាមកន្លែង ដើម្បីទទួលខុសត្រូវលើការរៀបចំផែនការបណ្តុះបណ្តាល ដោយផ្តោតលើតម្រូវការនៃមុខជំនាញ និងឱកាសចូលរួមរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ធ្វើយ៉ាងណាឱ្យការបណ្តុះបណ្តាលសម្រេចបាននូវគុណភាព និងមានប្រសិទ្ធភាព

- ពង្រីកកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាមរយៈការអនុវត្តមូលនិធិជាតិបណ្តុះបណ្តាល ដើម្បី កាត់បន្ថយភាពក្រីក្រ ឱ្យបានទូលាយបន្ថែមទៀត

- ជម្រុញឱ្យមានកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាមលិខិតបញ្ជាក់ឱ្យបានគ្រប់ខេត្ត-ក្រុង ។

## ង. ការពង្រឹងការងារគ្រប់គ្រង

រាជរដ្ឋាភិបាលនីតិកាលទី៣នៃរដ្ឋសភានេះ បានបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គឺសំដៅជាសំខាន់

ដោះស្រាយបញ្ហាមួយចំនួនដែលបានចោទឡើងក្នុងរយៈពេលកន្លងមកជាពិសេសបញ្ហាក្នុង ប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។ កន្លងមកផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ គ្រប់គ្រងដោយក្រសួងមួយចំនួនដូចជាក្រសួងអប់រំ យុវជន និងកីឡា អតីតក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។ល។ ជាហេតុធ្វើឱ្យការងារគ្រប់គ្រងក្នុងផ្នែកនេះមានលក្ខណៈស្មុគ-ស្មាញ គុណភាពបណ្តុះបណ្តាល មិនបានឆ្លើយតបទាំងស្រុងទៅតាមតម្រូវការដែលទីផ្សារការងារចង់បាន ។ ហេតុនេះ យោងតាមបេសកកម្មរបស់ខ្លួនក្នុងការគ្រប់គ្រង និងដឹកនាំវិស័យការងារ និងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្រសួងមានគោលបំណងពង្រឹងការងារគ្រប់គ្រងបន្ថែមទៀត ដើម្បីផ្សារភ្ជាប់កម្មវិធីបណ្តុះបណ្តាលជំនាញជាមួយវិស័យការងារ ឱ្យសមទៅនឹង ***រាជរដ្ឋាភិបាលដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព*** ។ ក្នុងគោលបំណងនេះ ក្រសួងបានរៀបចំសកម្មភាពការងារមួយចំនួនដូចខាងក្រោមនេះ :

## ៦.១ ការកែលំអរចនាសម្ព័ន្ធគ្រប់គ្រង

- ធ្វើវិមជ្ឈការនៃការងារគ្រប់គ្រង ដោយផ្តល់សិទ្ធិក្នុងការទទួលខុសត្រូវដល់អង្គភាពនីមួយៗ

ជាពិសេសគ្រឹះស្ថាន អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

- ជម្រុញឱ្យគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ នីមួយៗចេះរកចំណូលដោយខ្លួនឯង ដើម្បីនិរន្ត- ភាពរបស់គ្រឹះស្ថានសិក្សារបស់ខ្លួន
- ពង្រឹងការងារសណ្តាប់ធ្នាប់ វិន័យ តាមរយៈការប្រជុំធ្វើរបាយការណ៍ពីលទ្ធផលការងារជាប្រចាំ
- រៀបចំឱ្យមានការគ្រប់គ្រងជាលក្ខណៈប្រព័ន្ធ តាំងពីថ្នាក់ លើរហូតដល់មូលដ្ឋាន
- គ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលទាំងអស់ ត្រូវរៀបចំ ឱ្យមាននាយក នាយករង ប្រធាន អនុប្រធាន ការិយាល័យ និងប្រធាន អនុប្រធាន ក្រុមការងារតាមឋានានុក្រម ការងារ
- ជម្រុញឱ្យគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ឯកជនទាំងអស់មកចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈនាយកដ្ឋានគ្រប់គ្រង កិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។

## ៥.២ ការបែងចែកការទទួលខុសត្រូវ

- ថ្នាក់ជាតិមានគណៈកម្មាធិការជាតិបណ្ដុះបណ្ដាល ជាអ្នករៀបចំគោលនយោបាយ និងផែនការជាតិសម្រាប់វិស័យអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ និងនៅតាមខេត្ត-ក្រុង មានគណៈកម្មាធិការខេត្ត-ក្រុង បណ្ដុះបណ្ដាល
- ថ្នាក់កណ្ដាលមាន អគ្គនាយកដ្ឋានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈជាអ្នកតម្រង់ទិស និងសម្រប-សម្រួលការងារអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ
- តាមអង្គភាពនីមួយៗមានការបែងចែកតួនាទី ភារកិច្ចជូនដល់មន្ត្រីរាជការ និងគ្រូឱ្យបានច្បាស់លាស់ទៅតាមផ្នែក និងជំនាញនីមួយៗ ដើម្បីទទួលខុសត្រូវ
- ជម្រុញឱ្យអង្គភាពនីមួយៗត្រូវរៀបចំឱ្យមាន ផែនការយុទ្ធសាស្ត្ររយៈពេលមធ្យម វែង និងផែនការប្រចាំឆ្នាំរបស់ខ្លួន
- គ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈនីមួយៗមាន លទ្ធភាពរៀបចំ និងអភិវឌ្ឍដោយខ្លួនឯង ។

## ៦.៣ ការកែលំអ និងបង្កើតថ្មីនូវច្បាប់ បទបញ្ជា និងលិខិតបទដ្ឋាន

- ជម្រុញឱ្យនាយកដ្ឋានជំនាញពាក់ព័ន្ធនីមួយៗធ្វើការកែលំអ ច្បាប់ បទបញ្ជា លិខិតបទដ្ឋាននានា ដែលមានស្រាប់ និងបង្កើតថ្មីឱ្យបាន សមស្របតាមការរីកចំរើនរបស់ ប្រទេសជាតិ

- នាយកដ្ឋានជំនាញ
  អង្គភាពនីមួយៗត្រូវបង្កើតក្រុមការងារ
  តាក់តែងច្បាប់បទបញ្ជា និងលិខិតបទដ្ឋាន
- ក្រុមការងារតាក់តែងច្បាប់ បទបញ្ជា និងលិខិតបទដ្ឋាន ត្រូវសិក្សាស្រាវជ្រាវច្បាប់ បទបញ្ជា និងលិខិតបទដ្ឋាន នានាពីប្រទេសដទៃ
- ក្រុមការងារតាក់តែងច្បាប់ បទបញ្ជា និងលិខិតបទដ្ឋាន
  ត្រូវផ្សព្វផ្សាយឱ្យបានទូលាយនូវច្បាប់ បទបញ្ជា និងលិខិត

បទដ្ឋាន នានាដែលមានថ្មី ។

## ង.៤ ការពង្រឹងការពិនិត្យតាមដាន និងវាយតំលៃ

ពង្រឹងផ្នែកតាមដាន និងវាយតំលៃរបស់អង្គភាពនីមួយៗ មិនថានៅតាមនាយកដ្ឋាន ឬគ្រឹះស្ថាន អប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈទាំងថ្នាក់កណ្តាល និងថ្នាក់ខេត្ត-ក្រុង ជាពិសេសអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលជាអង្គភាពទទួលខុសត្រូវរួមត្រូវពិនិត្យតាមដានប្រសិទ្ធភាពការងារខាងក្នុង និងខាងក្រៅដោយកត់ត្រាទិន្នន័យធ្វើជាមូលដ្ឋានសំរាប់តម្រង់ទិស ក្នុងការរៀបចំនយោបាយអភិវឌ្ឍ លើវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស

និងវិជ្ជាជីវៈទៅថ្ងៃអនាគត ។ សកម្មភាពចាំបាច់ដែលត្រូវធ្វើរួមមាន :

- នាយកដ្ឋានជំនាញ និង គ្រឹះស្ថានអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈនីមួយៗត្រូវរៀបចំក្រុមការងារ មួយជាប្រចាំទទួលបន្ទុកការងារតាមដាន និងវាយតំលៃ នូវលទ្ធផលការងារ និងការវិវត្តរបស់អង្គភាពខ្លួន
- ក្រុមការងារតាមដាន និងវាយតំលៃត្រូវធ្វើការតាមដាន និងវាយតំលៃជាប្រចាំ តាមឋានានុក្រមការងារដោយភ្ជាប់ មកជាមួយរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីអ្វីដែល ខ្លួនបានពិនិត្យឃើញជាក់ស្តែងជាពិសេសនៅគ្រប់គ្រឹះស្ថាន អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈត្រូវតាមដាន សិក្ខាកាម សិស្ស និងនិស្សិត ដែលបានរៀនចប់មាន ការងារធ្វើ និងគ្មានការងារធ្វើ
- របាយការណ៍ការងារ អង្គភាពនីមួយៗត្រូវវាយការណ៍ជាប្រចាំតាមខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនថ្នាក់លើតាមឋានានុក្រមតាមឆ្នាំនីមួយៗគ្រប់អង្គភាពទាំងអស់

ត្រូវធ្វើការប្រជុំបូកសរុបនូវលទ្ធផលការងារ ដែលសម្រេចបាន បញ្ហាមិនទាន់សម្រេចបាន ឧបសគ្គ និងរៀបចំទិសដៅការងារបន្ត ។

## ច. ការលើកកំពស់ការប្រកួតប្រជែងមុខជំនាញ

ភាពប្រកួតប្រជែង តែងកើតមានឡើងគ្រប់ពេលគ្រប់ការងារ ។ ការប្រកួតប្រជែងនាំឱ្យកើតមានឡើងនូវការរីក-ចំរើន ។ ដូចនេះ ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវរៀបចំការប្រកួតប្រជែងជំនាញថ្នាក់ជាតិ ឬគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីទាក់ទាញទឹកចិត្តកូនសិស្ស ឬ មហាជនឱ្យចាប់អារម្មណ៍នូវអ្វីដែលគ្រឹះស្ថានបានធ្វើ និងផ្ដល់ជូនក្នុងគោលបំណងខិតខំលើកកំពស់សមត្ថភាពដល់សិក្ខាកាម សិស្ស និង និស្សិត ។

បច្ចុប្បន្ននេះ នៅបណ្ដាប្រទេសមួយចំនួនលើសកល-លោក បានរៀបចំធ្វើការប្រកួតប្រជែងនូវសមត្ថភាពមុខជំនាញសំខាន់ៗមួយចំនួនដែលគិតថាមានការចាំបាច់ ក្នុងន័យ ១). អភិវឌ្ឍសមត្ថភាពជំនាញរបស់យុវជន និងកម្មករនិយោជិត ២). ជម្រុញឱ្យការអប់រំបណ្ដុះបណ្ដាល បច្ចេកទេស និងវិជ្ជាជីវៈកាន់តែប្រសើរឡើង តាមរយៈដកយកបទពិសោធន៍ពីគ្នាទៅវិញទៅមក ពីគ្រឹះស្ថានសិក្សាមួយទៅគ្រឹះស្ថានសិក្សាមួយទៀត ៣). លើកទឹកចិត្ត ដល់សិក្ខាកាម សិស្ស និងនិស្សិតឱ្យយកចិត្តទុកដាក់លើជំនាញ និងសមត្ថភាពពិតប្រាកដ ៤).

ផ្តល់ការទទួលស្គាល់ចំពោះកម្មករ និយោជិតដែលមានសមត្ថភាពខ្ពស់ ។ ជាក់ស្តែង ដូចក្នុងឆ្នាំ២០០៦នេះ ក្រសួងបានបញ្ជូននិស្សិត ២រូប ជំនាញជាងផ្សារ ១រូប និងអគ្គិសនី ១រូប ទៅចូលរួមការប្រកួតប្រជែងនៅប្រទេសប៊្រុយណេ ក្នុងក្របខ័ណ្ឌជាអាស៊ាន ហើយលទ្ធផលនៃការប្រកួតនោះ សរបញ្ជាក់ឱ្យឃើញថាបេក្ខជនទាំង២រូបនោះនៅមានកង្វះខាតសមត្ថភាព ។ ហេតុនេះ ក្រសួងនឹងធ្វើសកម្មភាព ការងារមួយចំនួនដូចខាងក្រោម ដើម្បីឈានដល់ការរៀបចំពិធីប្រកួតប្រជែងមុខជំនាញទាំងក្នុងប្រទេស ក៏ដូចការចូលរួមប្រកួតជាលក្ខណៈអន្តរជាតិ :

- ធ្វើការបណ្តុះបណ្តាលមន្ត្រីជំនាញ
- រៀបចំនីតិវិធីនៃការប្រកួតប្រជែងមុខជំនាញ
- បង្កើតក្រុមការងារ
  បច្ចេកទេសសិក្សាស្រាវជ្រាវចងក្រង ឯកសារបច្ចេកទេស
- ចូលរួមធ្វើការផ្លាស់ប្តូរបទពិសោធន៍ជាមួយបណ្តាប្រទេសក្នុងតំបន់ និងសកលលោក
- រៀបចំការប្រកួតមុខជំនាញថ្នាក់ជាតិ និងអន្តរជាតិ ។

## ឆ. ការផ្តត់ផ្គង់ហិរញ្ញវត្ថុ

ជាការពិត យើងត្រូវទទួលស្គាល់ថាថវិការដ្ឋពុំអាចធានាបានតាមតម្រូវការនៃការអភិវឌ្ឍវិស័យអប់រំ បណ្តុះ-បណ្តាលបច្ចេកទេស និងវិជ្ជាជីវៈបានទេព្រោះទាមទារនូវការចំណាយច្រើន ។ ដូចនេះដើម្បីធានាឱ្យបានដំណើរការបណ្តុះ-

បណ្តាល ចាំបាច់ត្រូវមានប្រភពហិរញ្ញវត្ថុជាច្រើន ពិសេសប្រភពពីដៃគូអ្នកពាក់ព័ន្ធ ទាំងអស់ដូចជា :

- ប្រភពសាធារណៈ
- សហគមន៍
- សមាគមវិជ្ជាជីវៈ
- អង្គការមិនមែនរដ្ឋាភិបាល
- គ្រឹះស្ថានអប់រំបណ្តុះបណ្តាលខ្លួនឯងផ្ទាល់
- ប្រភពពីដៃគូអភិវឌ្ឍន៍ផ្សេងៗទៀត ។